CITY OF LONGBEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១ ខែកក្កដាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# លោកអភិបាលរដ្ឋ Newsom បានប្រកាសបិទជាចាំបាច់នូវកន្លែងទទួលទានអាហារក្នុងហាងនិងកន្លែងខាងក្នុងនៅតាមសារមន្ទីរនៅទូទាំងខោនធី Los Angeles

*រដ្ឋក៏បានចេញគោលនយោបាយថ្មីទាក់ទងនឹងរបាំងមុខផងដែរ*

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ថ្ងៃនេះអភិបាលរដ្ឋកាលីហ្វ័រញ៉ាលោក Gavin Newsom បានប្រកាសបិទជាចាំបាច់នូវកន្លែងទទួលទានអាហារក្នុងហាងនិងកន្លែងខាងក្នុងនៅតាមសារមន្ទីរនៅទូទាំងខោនធី Los Angeles ក្នុងគោលបំណងទប់ស្កាត់ការរីករាលដាលនៃជម្ងឺ COVID-19។ ទីធ្លាខាងក្រៅនៅតាមសារមន្ទីរនិងអាងចិញ្ចឹមត្រីនៃប៉ាស៊ីហ្វិក (Aquarium of the Pacific) អាចនៅបើកបានហើយភោជនីយដ្ឋានទាំងឡើយអាចដំណើរការសម្រាប់តែការទទួលទានអាហារនៅខាងក្រៅ ការមកយកអាហារនៅតាមដងផ្លូវនិងមាត់ទ្វារ និងការដឹកជញ្ជូនអាហារទៅដល់ផ្ទះតែប៉ុណ្ណោះ។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "នៅពេលដែលអត្រានៃការឆ្លងជម្ងឺ COVID-19 នៅតែបន្តកើនឡើងយើងត្រូវតែបន្តការពារសហគមន៍របស់យើង។ យើងគាំទ្រការសម្រេចចិត្តរបស់លោកអភិបាលរដ្ឋក្នុងការបិទទីធ្លាខាងក្នុងទាំងនេះហើយយើងនឹងធ្វើការជាមួយក្រុមការងារទីក្រុងរបស់យើងដើម្បីផ្តល់ជំរើសខាងក្រៅដល់អាជីវកម្មតាមរយៈគំនិតផ្តួចផ្តើមបើកចំហរផ្លូវនៅឡុងប៊ិច។"

ការបិទជាចាំបាច់នឹងចូលជាធរមាននៅយប់នេះគឺបន្ទាប់ពីពាក់កណ្ដាលអធ្រាត្រ (នៅម៉ោង ១២:០១ នាទីថ្ងៃទី ២ ខែកក្កដាឆ្នាំ ២០២០)។ បទបញ្ជាសុខភាពរបស់ទីក្រុងឡុងប៊ិចដែលត្រូវបានកែប្រែដែលមានព័ត៌មានលំអិតស្ដីពីការបិទទាំងនេះនឹងចេញផ្សាយនៅថ្ងៃនេះនៅលើគេហទំព័រ longbeach.gov/COVID19។

យោងតាមគោលការណ៍ណែនាំរបស់រដ្ឋសម្រាប់ដំណើរការបើកឡើងវិញឡុងប៊ិចដែលជាទីក្រុងដែលមានមន្ទីរសុខាភិបាលផ្ទាល់ខ្លួនត្រូវបានរាប់បញ្ចូលជាមួយនឹងខោនធី Los Angeles។ ទោះបីជារដ្ឋពិចារណាលើឡុងប៊ិចដោយឡែកក៏ទិន្នន័យរបស់ឡុងប៊ិចនៅតែធ្វើឲ្យទីក្រុងនេះស្ថិតក្នុងបញ្ជីការបិទជាចាំបាច់ដដែល។

ចាប់តាំងពីទិវារំឭកថ្ងៃចងចាំអត្រាវិជ្ជមាននៃជម្ងឺ COVID-19 នៅឡុងប៊ិចបានកើនឡើងពី ៨,៤% ទៅដល់ ១០,៨% ដោយចំនួនករណីសរុបកើនឡើងពី ១.៦០៥ គិតត្រឹមថ្ងៃទី ២៥ ខែឧសភាដល់ចំនួន ៤.២២០ គិតត្រឹមថ្ងៃទី ៣០ ខែមិថុនា។ ចំនួនកុមារនិងអ្នកវ័យក្មេងនៅឡុងប៊ិចដែលទទួលបានលទ្ធផលតេស្ដវិជ្ជមានសម្រាប់ជម្ងឺ COVID-19 កំពុងតែកើនឡើងយ៉ាងរហ័ស។ ក្នុងពេលដំណាលគ្នាករណីឆ្លងក្នុងចំណោមកុមារនិងក្មេងជំទង់ (អាយុ ០-១៩ ឆ្នាំ) បានកើនឡើងពី ១០៨ ដល់ទៅ ៣៩៤ ឬ ២៦៥%។ ចាប់តាំងពីទិវារំឭកថ្ងៃចងចាំករណីឆ្លងក្នុងចំណោមមនុស្សវ័យក្មេងដែលមានអាយុពី ២០-២៩ ឆ្នាំបានកើនឡើងដល់ ១៨០% គឺពីចំនួន ៣០៩ ទៅដល់ ៨៦៥ ករណី។

ការទៅបរិភោគអាហារក្រៅផ្ទះនិងការទៅទស្សនានៅសារមន្ទីរនិងអាងចិញ្ចឹមត្រីគឺជាពេលវេលាដែលសាធារណជនជុំគ្នាក្នុងរយៈពេលយូរហើយជារឿយៗអាចមានទំនាក់ទំនងជាមួយនឹងមនុស្សដែលមិនរស់នៅជាមួយហើយគឺបែបនេះក្នុងករណីបរិភោគអាហារក្នុងហាងដោយមិនពាក់របាំងមុខផងដែរ។ ធាតុផ្សំនៃកត្តាទាំងនេះនាំឱ្យសន្និដ្ឋានបានថាការញ៉ាំអាហារក្នុងហាងនិងការចំណាយពេលនៅកន្លែងខាងក្នុងនៅតាមសារមន្ទីរឬអាងចិញ្ចឹមត្រីធ្វើឱ្យសាធារណជនមានហានិភ័យខ្ពស់ក្នុងការឆ្លងជម្ងឺ COVID-19។ ដោយអនុញ្ញាតឱ្យមានសកម្មភាពទាំងនេះត្រូវតែនៅខាងក្រៅនោះអត្រានៃកំរិតឆ្លងអាចថយចុះ។ បទបញ្ជារបស់រដ្ឋក៏បានបង្ហាញពីទីតាំងដែលមានហានិភ័យខ្ពស់ដែលមិនទាន់អនុញ្ញាតឱ្យបើកនៅឡុងប៊ិចដូចជាមជ្ឈមណ្ឌលកម្សាន្តជាលក្ខណៈគ្រួសារនិងរោងកុននិងអាជីវកម្មដែលមិនទាន់មាននៅក្នុងទីក្រុងនៅឡើយដូចជាបន្ទប់កាតជាដើម។

ទីក្រុងឡុងប៊ិចកំពុងធ្វើការពង្រីកតំបន់បរិភោគអាហារខាងក្រៅដើម្បីជួយដល់អាជីវកម្មនិងអតិថិជនដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមបើកចំហរផ្លូវ។ មន្ទីរសាធារណការក្រុងកំពុងធ្វើការយ៉ាងសកម្មជាមួយម្ចាស់ភោជនីយដ្ឋាននៅទូទាំងទីក្រុងដើម្បីពង្រីកចិញ្ចើមផ្លូវដែលត្រូវបានកែប្រែជាកន្លែងបរិភោគអាហារនៅខាងក្រៅ។ រហូតមកដល់បច្ចុប្បន្នចិញ្ចើមផ្លូវចំនួន ១៨ នៅមុខភោជនីយដ្ឋានតាមដងផ្លូវបរិភោគអាហារដ៏មមាញឹកដូចជា Belmont Shore, Downtown, Retro Row និង Bixby Knolls ត្រូវបានពង្រីកដោយមានកន្លែង ៧ បន្ថែមទៀតដែលនឹងត្រូវពង្រីកនៅថ្ងៃនេះនិងថ្ងៃស្អែកហើយមានចិញ្ចើមផ្លូវដែលគ្រោងទុកជាច្រើនទៀតសម្រាប់ការពង្រីកនៅថ្ងៃខាងមុខ។

ភោជនីយដ្ឋានក៏អាចផ្តល់ជូននូវសេវាកម្មម្ហូបអាហារតាមឡានដែលជាផ្នែកមួយនៃប្រតិបត្តិការធម្មតារបស់ពួកគាត់។ ភោជនីយដ្ឋានអាចទទួលការបញ្ជាទិញនិងដឹកជញ្ជូនម្ហូបនៅក្នុងចំណតផ្ទាល់ខ្លួនរបស់ពួកគាត់ដល់ចំហៀងឡានដោយមិនចាំបាច់មានការអនុញ្ញាតបន្ថែមឡើយ។ សេវាកម្មទាក់ទងនឹងគ្រឿងស្រវឹងគឺមិនត្រូវបានអនុញ្ញាតឲ្យជាផ្នែកមួយនៃប្រតិបត្តិការបម្រើតាមឡានរបស់ភោជនីយដ្ឋាននោះទេ។ អ្នកដែលមានបំណងកែប្រែកន្លែងចតរថយន្តរបស់ពួកគេឬលំហូរចរាចរណ៍ឬផ្តល់នូវតង្រ្គិកន្លែងអង្គុយខាងក្រៅឬការកម្សាន្តផ្សេងៗត្រូវបានណែនាំឱ្យដាក់ពាក្យសុំលិខិតអនុញ្ញាតសម្រាប់ព្រឹត្តិការណ៍ពិសេស - ការអនុញ្ញាតការកម្សាន្តម្តងម្កាល។ ឯកសារពាក្យសុំមាននៅលើអ៊ីនធឺណិតហើយព័ត៌មានបន្ថែមអាចរកបានដោយទូរស័ព្ទទៅលេខ (562) 570-5333។

ការបិទជាចាំបាច់ទាំងនេះគឺបន្ថែមលើការបិទបារ៍និងការបិទឆ្នេរសមុទ្រព្រមទាំងការលប់ចោលការបង្ហាញកាំជ្រួចនៅឡុងប៊ិចនៅចុងសប្តាហ៍នៃទិវាឯករាជ្យជាតិនេះ។

ម្ចាស់អាជីវកម្មដែលមានសំណួរទាក់ទងនឹងការបិទជាចាំបាច់នេះអាចទូរស័ព្ទទៅខ្សែព័ត៌មានអាជីវកម្មរបស់ទីក្រុងឡុងប៊ិចចន្លោះម៉ោង ៩ ព្រឹកដល់ម៉ោង ៥ ល្ងាចពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រនៅលេខ 562.570.4BIZ។

បទបញ្ជាសុខភាពក៏បានចេញច្បាប់ថ្មីទាក់ទងនឹងរបាំងមុខផងដែរ។ ការពាក់រម៉ាស់ដែលមានសន្ទះទប់ខ្យល់ឲ្យហូមួយផ្លូវ (ដែលជាទូទៅមានរាងជាស៊ីឡាំងប្លាស្ទិចនិងប្រហែលទំហំកាក់ ២៥ សេនដែលអាចមាននៅខាងមុខឬនៅចំហៀងមួនណានៃរបាំងមុខ) គឺត្រូវហាមឃាត់។ របាំងមុខទាំងនេះគឺរចនាឡើង

ដើម្បីជួយសម្រួលដល់ការដកដង្ហើមចេញនិងបណ្តាលឱ្យដំណក់ទឹកមាត់ក្លាយចេញពីរបាំងមុខនិងធ្វើឱ្យអ្នកផ្សេងដែលនៅជិតអាចគ្រោះថ្នាក់។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #